# បេសកកម្មស៊ីស៊ីឌី

## CCD MISSION

អស់លោកស្នេហា វប្បធម៌ខេមរា ពីគ្រប់ទិសទី
ស៊ីស៊ីឌីខ្ញុំ ស្វាគមន៍សាមគ្គី រួមដៃសំភី រក្សាមរតក។

តពីដូនតា ជ្រោងខ្ពស់ថ្លៃថ្លា កុំបីដំអក់
រួមទាំងកូនចៅ ព្យាយាមតក់ៗ វប្បធម៌ខ្មែរដក់ គង់វង់តទៅ។

ខ្មែរពូជធ្លាប់ល្បី វប្បធម៌អរិយ ធម៌ខ្ពស់សន្ធៅ
របាំតន្ត្រី ដូនតាទុកនៅ រួមគ្នាឥឡូវ អោយទាន់វេលា។

ស៊ីស៊ីឌីខ្ញុំ ប្រុសស្រីតូចធំ សូមតែរួមគ្នា
ជួយច្រើនឬតិច តាមតែសទ្ធា យើងខ្ញុំវន្ទា ជ្រោងសហគមន៍។

ច្រើនឆ្នាំមកនេះ ស៊ីស៊ីឌីរិះ គិតប្រមូលផ្តុំ
ពលរដ្ឋអាមេរិក និងភ្ញៀវអោយជុំ ស្គាល់វប្បធម៌ខ្ញុំ ជារៀងរាល់ឆ្នាំ។

លោកអ្នកប្រុសស្រី មិត្តដ៏ប្រពៃ ជួយដឹងជួយចាំ
ស៊ីស៊ីឌីខ្ញុំ ជ្រោងខ្មែរវប្បកម្ម អោយរស់ដុះដាំ ក្នុងសហរដ្ឋ។

---

និពន្ធដោយ ច័ន្ទដាវី យីម Composed By Chan Davy Yim